**អេ អាយ អេ (ខេមបូឌា) ឡាយហ្វ៍ អ៊ិនសួរេន ម.ក**
អគារ ជីអាយអេ ថៅអឺរ ជាន់ទី៣១ ផ្លូវសុភមង្គល ភូមិ១៤ សង្កាត់
ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

លេខទូរស័ព្ទ៖ (855) 86 999 242

AIA.COM.KH

# អត្ថបទសារព័ត៌មាន

## អេ អាយ អេ ខេមបូឌា និងប្រៃសណីយ៍កម្ពុជា ចាប់ដៃគ្នាបង្កើនការប្រើប្រាស់សេវាធានារ៉ាប់រង ក្នុងគោលបំណងជួយប្រជាជនកម្ពុជា ឱ្យរស់នៅមានសុខភាព និងជីវិតកាន់តែប្រសើរ

ភ្នំពេញ ថ្ងៃទី 5 ខែមេសា ឆ្នាំ 2023 – ក្រុមហ៊ុន អេ អាយ អេ (ខេមបូឌា) ឡាយហ្វ៍ អ៊ិនសួរេន ម.ក (“អេ អាយ អេ ខេមបូឌា”) បង្ហាញពីកិច្ចខិតខំប្រឹងប្រែងក្នុងការបង្កើនការប្រើប្រាស់សេវាធានារ៉ាប់រង និងបន្តជួយប្រជាជនកម្ពុជាឱ្យរស់នៅមានសុខភាព និងជីវិតកាន់តែប្រសើរ ដោយក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិតឈានមុខគេរបស់ព្រះរាជាណាចក្រកម្ពុជាមួយនេះបានចុះកិច្ចព្រមព្រៀងភាពជាដៃគូផ្តាច់មុខជាមួយ ប្រៃសណីយ៍កម្ពុជា។

ដើម្បីអបអរឱកាសដ៏ពិសេសនេះ អតិថិជនរបស់ប្រៃសណីយ៍កម្ពុជា នឹងទទួលបានការធានារ៉ាប់រងចំនួន 500 ដុល្លារ ឥតគិតថ្លៃ លើករណីមរណភាព និងពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍។ ការផ្តល់ជូននេះនឹងមានប្រសិទ្ធភាពចាប់ពីកាលបរិច្ឆេទនៃកិច្ចព្រមព្រៀងតទៅ និងនៅពេលដែលអតិថិជនស្កេន QR កូដ របស់ អេ អាយ អេ ខេមបូឌា នៅតាមការិយាល័យប្រៃសណីយ៍កម្ពុជា។

QR កូដ ទាំងនេះនឹងដាក់ឱ្យប្រើប្រាស់ នៅក្នុងអំឡុងខែមេសានេះនៅការិយាល័យកណ្តាលរបស់ប្រៃសណីយ៍កម្ពុជានៅវត្តភ្នំ និងសាខាទូទាំងប្រទេស។

ការផ្តល់ជូននេះគឺចំនុចចាប់ផ្តើមនៃកិច្ចសហការរយៈពេលប្រាំឆ្នាំនេះតែប៉ុណ្ណោះ។ ផលិតផល និងសេវាកម្មជាច្រើនទៀតរបស់ អេ អាយ អេ ខេមបូឌា នឹងដាក់ឱ្យប្រើប្រាស់ ដើម្បីជួយសម្រួលដល់អតិថិជនក្នុងការទទួលបានការការពារ ក៏ដូចជាការទទួលបានព័ត៌មានអំពីសេវាទាំងនោះ។

កិច្ចព្រមព្រៀងនេះជួយពង្រឹងការប្តេជ្ញាចិត្តរយៈពេលវែងរបស់ អេ អាយ អេ ខេមបូឌា ក្នុងការលើកកម្ពស់ការយល់ដឹងអំពីធានារ៉ាប់រង និងជួយសម្រួលដល់ការទទួលបានព័ត៌មាននានាពីផលិតផល និងសេវាកម្មធានារ៉ាប់រង។ ការសហការនេះជួយឱ្យ អេ អាយ អេ ខេមបូឌា ពង្រីកវិសាលភាពរបស់ខ្លួនក្នុងការផ្តល់ការការពារផ្នែកហិរញ្ញវត្ថុដល់ប្រជាជនកាន់តែច្រើន និងបង្កើនការយល់ដឹងផ្នែកធានារ៉ាប់រងនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

សម្រាប់ប្រៃសណីយ៍កម្ពុជា ភាពជាដៃគូនេះជាសេវាកម្មបន្ថែមផ្តល់ជូនអតិថិជន ទាំងអត្ថប្រយោជន៍លើការការពារហិរញ្ញវត្ថុ និងភាពងាយស្រួលក្នុងការប្រើប្រាស់ផលិតផលរបស់ អេ អាយ អេ ខេមបូឌា នៅទីតាំងផ្សេងៗកាន់តែច្រើន។

**អេ អាយ អេ (ខេមបូឌា) ឡាយហ្វ៍ អ៊ិនសួរេន ម.ក**
អគារ ជីអាយអេ ថៅអឺរ ជាន់ទី៣១ ផ្លូវសុភមង្គល ភូមិ១៤ សង្កាត់
ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

លេខទូរស័ព្ទ៖ (855) 86 999 242

AIA.COM.KH

# អត្ថបទសារព័ត៌មាន

ក្រៅពីការជំរុញកំណើនសេដ្ឋកិច្ច និងការរួមចំណែកក្នុងការឆ្ពោះទៅរកការអភិវឌ្ឍសង្គម យើងឃើញថា អេ អាយ អេ ខេមបូឌា និង ប្រៃសណីយ៍កម្ពុជា មានគោលដៅស្របគ្នាជាមួយនឹងចក្ខុវិស័យរបស់រាជរដ្ឋាភិបាលក្នុងការកសាងសេដ្ឋកិច្ច និងសង្គមឌីជីថលឱ្យកាន់តែរីកចម្រើន។

ការចុះហត្ថលេខាលើកិច្ចព្រមព្រៀងនេះត្រូវបានប្រារព្ធឡើងនៅទីស្នាក់ការកណ្តាលរបស់ អេ អាយ អេ ខេមបូឌា ដោយមានការផ្តល់កិត្តិយសចូលរួមពី លោក ថេន សំរិសុទ្ធ អគ្គនាយកប្រៃសណីយ៍កម្ពុជា និងលោក Andrew Loh អគ្គនាយកក្រុមហ៊ុន អេ អាយ អេ ខេមបូឌា ជាមួយនឹងវត្តមានរបស់លោក Tan Hak Leh អគ្គនាយកប្រចាំតំបន់ របស់AIA Group ថ្នាក់ដឹកនាំជាន់ខ្ពស់មកពី AIA Group អេ អាយ អេ ខេមបូឌា និង ប្រៃសណីយ៍កម្ពុជា ទីប្រឹក្សាផែនការជីវិត និងបុគ្គលិកផងដែរ។

លោក ថេន សំរិសុទ្ធ មានប្រសាសន៍ថា៖ “ប្រៃសណីយ៍កម្ពុជា មានមោទកភាពក្នុងការធ្វើការជាមួយ អេ អាយ អេ ខេមបូឌា ដើម្បីផ្តល់នូវភាពងាយស្រួលដល់អតិថិជនក្នុងការប្រើប្រាស់ផលិតផល និងសេវាកម្មពី អេ អាយ អេ ខេមបូឌា។ ភាពជាដៃគូនេះក៏នឹងអនុញ្ញាតឱ្យប្រៃសណីយ៍កម្ពុជា ពង្រីកសេវាកម្មជូនអតិថិជនរបស់យើងលើសពីការផ្តល់ជូនកន្លងមក។”

លោក Andrew Loh បានមានប្រសាសន៍ថា៖ “ចំពោះ អេ អាយ អេ ខេមបូឌា អ្វីគ្រប់យ៉ាងដែលយើងធ្វើ គឺស្របតាមគោលបំណងរបស់យើងក្នុងការផ្តល់ជូនប្រជាជនកម្ពុជានូវសុខភាព និងជីវិតកាន់តែប្រសើរ។ ខ្ញុំសូមអរគុណដល់ប្រៃសណីយ៍កម្ពុជា ដែលគាំទ្រពួកយើង និងជួយ អេ អាយ អេ ខេមបូឌា ផ្តល់អត្ថប្រយោជន៍បន្ថែមដល់អតិថិជន ក៏ដូចជាការបង្ហាញពីអត្ថប្រយោជន៍ជាច្រើននៃធានារ៉ាប់រងក្នុងការទ្រទ្រង់សុខភាព និងសុវត្ថិភាពហិរញ្ញវត្ថុ។”

“តាមរយៈកិច្ចខិតខំប្រឹងប្រែងទាំងនេះ យើងអាចជួយប្រជាជនកម្ពុជាឱ្យឆ្ពោះទៅមុខកាន់តែប្រសើរ ដែលពួកគេអាចមានលទ្ធភាពកាន់តែប្រសើរក្នុងការរៀបចំផែនការហិរញ្ញវត្ថុ សម្រេចបាននូវគោលដៅហិរញ្ញវត្ថុ និងបង្កើតមូលដ្ឋានគ្រឹះដ៏រឹងមាំសម្រាប់សុខុមាលភាពនាពេលអនាគតរបស់ពួកគេ។”

សម្រាប់ព័ត៌មានបន្ថែមអំពី អេ អាយ អេ ខេមបូឌា ឬស្វែងយល់ពីព័ត៌មានលម្អិតលើដំណោះស្រាយការពារអាយុជីវិត ជំងឺធ្ងន់ធ្ងរ គ្រោះថ្នាក់ចៃដន្យ សូមទាក់ទង AIA Client Care តាមរយៈលេខ 086 999 242 ចូលទៅកាន់ aia.com.kh ផ្ញើអ៊ីមែលមកកាន់ kh.marketing@aia.com ឬចូលទៅកាន់គេហទំព័រ www.facebook. com/AIACambodia ។

**អេ អាយ អេ (ខេមបូឌា) ឡាយហ្វ៍ អ៊ិនសួរេន ម.ក**
អគារ ជីអាយអេ ថៅអឺរ ជាន់ទី៣១ ផ្លូវសុភមង្គល ភូមិ១៤ សង្កាត់
ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

លេខទូរស័ព្ទ៖ (855) 86 999 242

AIA.COM.KH

# អត្ថបទសារព័ត៌មាន

***អំពី អេ អាយ អេ ខេមបូឌា***

*ក្រុមហ៊ុនធានារ៉ាប់រង អេ អាយ អេ ខេមបូឌា គឺជាបុត្រសម្ព័ន្ធនៃ AIA Group មានក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិតនៅទូទាំងតំបន់អាស៊ីដែលស្ថិតក្នុងបញ្ជីឈ្មោះសាធារណៈឯករាជ្យធំជាងគេ។ ក្រុមហ៊ុនមានវត្តមាននៅលើទីផ្សារចំនួន 18 ប្រទេសនៅអាស៊ីប៉ាស៊ីហ្វិក - សាខាគ្រប់គ្រងទាំងស្រុង។*

*ចាប់តាំងពីបើកដំណើរការនៅកម្ពុជា រាល់សកម្មភាពរបស់ អេ អាយ អេ ខេមបូឌា ធ្វើឡើងស្របតាមគោលបំណង ក្នុងការជួយឱ្យប្រជាជនកម្ពុជាឱ្យរស់នៅមានសុខភាព និងជីវិតកាន់តែប្រសើរ។ ចាប់តាំងពីចាប់ផ្ដើមអាជីវកម្មក្នុងឆ្នាំ 2017 យើងបានក្លាយជាក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិតដំបូងបង្អស់នៅកម្ពុជា ផ្ដល់ការការពាររហូតដល់ 26 ស្ថានភាពជំងឺធ្ងន់ធ្ងរ។ ក្នុងនាមជាក្រុមហ៊ុនធានារ៉ាប់រងឈានមុខគេមួយនៅកម្ពុជា  អេ អាយ ខេ ខេមបូឌា ផ្ដល់ជូននូវដំណោះស្រាយជីវិតឈានមុខគេនៅលើទីផ្សារសម្រាប់ប្រជាជនកម្ពុជាគ្រប់មជ្ឈដ្ឋាន   រាប់ចាប់ពីគម្រោងធានារ៉ាប់រងសំខាន់ៗដែលបង្កើតឡើងស្របតាមតម្រូវការជាក់លាក់  ដែលរួមមានគម្រោងការពារលើជំងឺធ្ងន់ធ្ងរ  គ្រោះថ្នាក់ចៃដន្យ  ថ្លៃសម្រួលការសម្រាកព្យាបាលនៅមន្ទីរពេទ្យ និងជំនួយសង្គ្រោះបន្ទាន់នៅក្រៅប្រទេស។*

*អេ អាយ អេ ខេមបូឌា ផ្ដោតសំខាន់លើការណែនាំ និងជម្រុញឱ្យប្រជាជនក្នុងសង្គមទទួលយកទម្លាប់ល្អៗ ក៏ដូចជាមធ្យោបាយដើម្បីឱ្យពួកគាត់ទទួលបាននូវសុខភាពល្អ តាមរយៈគំនិតផ្តួចផ្តើម រួមមានកិច្ចសហការ ជាមួយក្រសួងកិច្ចការនារី ដើម្បីពង្រឹងលើសមភាពយេនឌ័រនិងសិទ្ធិស្ត្រី ការលើកកម្ពស់ការយល់ដឹងអំពីជំងឺមហារីកសុដន់ តាមរយៈយុទ្ធនាការប្រចាំឆ្នាំ Fit for Hope របស់យើងជាដើម។*

*យើងក៏ចូលរួមជួយលើកស្ទួយកុមារដែលជួបបញ្ហាជីវភាពរាប់ពាន់នាក់ផងដែរ   ដោយតាមរយៈឧបត្ថម្ភដល់លីគបាល់ទាត់ AIA-ISF   ដែលជាលីគបាល់ទាត់ថ្នាក់មូលដ្ឋានធំជាងគេនៅកម្ពុជា។ជាងនេះទៀតសោធ   យើងក៏សហការជាមួយក្លឹប Tottenham Hotspur ក្នុងក្របខណ្ឌ English Premier League ដែលជាដៃគូសកល និងជាក្លឹបបាល់ទាត់កំពូលនៅលើពិភពលោក ដើម្បីធានាថាកុមារទាំងនោះទទួលបានការអប់រំដែលពួកគេសមនឹងទទួលបាន។*

*អេ អាយ អេ ខេមបូឌា គឺជាក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិតកម្ពុជាតែមួយគត់ដែលបានទទួលពានរង្វាន់ "ក្រុមហ៊ុនល្អបំផុតសម្រាប់ការងារនៅអាស៊ី (Best Companies to Work for in Asia)" ពី HR Asia ក្នុងរយៈពេល 3ឆ្នាំជាប់គ្នា 2020, 2021 និង 2022។ អេ អាយ អេ ខេមបូឌា មានការិយាល័យកណ្ដាលនៅទីក្រុងភ្នំពេញ និងបច្ចុប្បន្នបានពង្រីកសាខានៅខេត្តសៀមរាប កំពត កំពង់ចាម និងបាត់ដំបង។*

**អេ អាយ អេ (ខេមបូឌា) ឡាយហ្វ៍ អ៊ិនសួរេន ម.ក**
អគារ ជីអាយអេ ថៅអឺរ ជាន់ទី៣១ ផ្លូវសុភមង្គល ភូមិ១៤ សង្កាត់
ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

លេខទូរស័ព្ទ៖ (855) 86 999 242

AIA.COM.KH

# អត្ថបទសារព័ត៌មាន

*ព័ត៌មានបន្ថែមតាមរយៈគេហទំព័រ www.aia.com.kh*

*ទំនាក់ទំនងសារព័ត៌មាន*
*ម៉េង ដាណែត*
*ប្រធានផ្នែកទំនាក់ទំនងសាធារណៈ*
*អេ អាយ អេ (ខេមបូឌា) ឡាយហ្វ៍ អ៊ិនសួរេន ម.ក*
[Daneth-d.Meng@aia.com](mailto:Daneth-d.Meng@aia.com)